## រឿងទី៨៖ ក្រុមជំនុំដើម

**ខគម្ពីរ៖ កិច្ចការ២:៤**

អ្នកទាំងនោះបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយចាប់ផ្ដើមនិយាយភាសាផ្សេងៗពីគ្នា តាមព្រះវិញ្ញាណប្រោសប្រទានអោយ

ព្រះយេស៊ូបានសុគតដោយត្រូវឆ្កាងនៅលើឈើឆ្កាង ហើយបីថ្ងៃក្រោយទ្រង់ក៏មានព្រះជន្មរស់ឡើងវិញ។

បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញហើយ ៤០ថ្ងៃក្រោយ ទ្រង់ក៏យាងទៅស្ថានសួគ៌វិញ។

ក្រោយព្រះយេស៊ូបានយាងទៅស្ថានសួគ៌ ពួកសាវកទាំងអស់បានឡើងទៅបន្ទប់ខាងលើដើម្បីអធិស្ឋានជាមួយគ្នា។

ក្រោយកន្លងបាន១០ថ្ងៃ ពិធីបុណ្យថ្ងៃទី៥០របស់ជនជាតិយូដាក៏បានមកដល់។

ដូចសព្វមួយដង ពួកសាវករបស់ព្រះយេស៊ូនិងមនុស្សផ្សេងទៀតនៅតែបន្តជួបជុំគ្នាអធិស្ឋាននៅក្នុងបន្ទប់ខាងលើ។

ប៉ុន្តែ ភ្លាមនោះស្រាប់តែមានឮសូរសន្ធឹកពីលើមេឃ ដូចខ្យល់បក់បោកយ៉ាងខ្លាំង ពេញក្នុងផ្ទះដែលគេនៅ។

ក្នុងពេលជាមួយគ្នានោះ ក៏មានអណ្ដាតភ្លើងក្រហមបែកចេញពីគ្នាចុះមកសណ្ឋិតលើពួកសាវក។

រំពេចនោះ ពួកសាវកដែលទទួលបានការជ្រមុជដោយព្រះវិញ្ញាណ ចាប់ផ្ដើមនិយាយភាសាផ្សេងៗពីគ្នា ដែលសូម្បីខ្លួនគេ ក៏មិនដឹងថាជាអ្វីដែរ។

លោកពេត្រុសបានចាប់ផ្ដើមអធិប្បាយព្រះបន្ទូលទៅកាន់ហ្វូងមនុស្ស។

«ក្រោយពីព្រះយេស៊ូទ្រង់បានយាងឡើងទៅស្ថានសួគ៌វិញ ព្រះវិញ្ញាណដ៏វិសុទ្ធក៏យាងមកជួយឱ្យមនុស្សបានយល់ដឹងពីគ្រប់ទាំងព្រះបន្ទូលដែលព្រះយេស៊ូបានបង្រៀន។

ព្រះជាម្ចាស់បានបញ្ជូនព្រះយេស៊ូឱ្យមកផែនដីនេះ ដើម្បីសង្គ្រោះអ្នករាល់គ្នា។

អស់អ្នកដែលបានស្ដាប់ការអធិប្បាយរបស់ពេត្រុសបានសួរថា៖ «យើងខ្ញុំគួរធ្វើដូចម្ដេច ទើបអាចទទួលបានការសង្គ្រោះ?»

«ចូរជឿព្រះយេស៊ូ ហើយទទួលបុណ្យជ្រមុជទឹកនៅក្នុងព្រះនាមព្រះយេស៊ូ នោះអំពើបាបនឹងត្រូវបានអត់ទោស»។

ពេលបានលឺពេត្រុសនិយាយហើយ មនុស្សទាំងអស់មានការប៉ះពាល់ចិត្តជាខ្លាំង។

នៅថ្ងៃនោះ មានមនុស្សជាងបីពាន់នាក់បានជឿតាមរយៈពេត្រុស ហើយទទួលធ្វើបុណ្យជ្រមុជទឹក។

ពួកសាវករបស់ព្រះយេស៊ូ និងអ្នកដែលជឿព្រះយេស៊ូ បានមកព្រះវិហារជួបជុំគ្នា អធិស្ឋានអរព្រះគុណព្រះជាម្ចាស់រៀងរាល់ថ្ងៃ។

ហើយពួកគេទាំងនោះ បានលក់ទ្រព្យសម្បត្តិខ្លួន ចែកទានដល់អ្នកក្រខ្សត់។



ក្រោយព្រះវិញ្ញាណទ្រង់សណ្ឋិត ហើយការទាំងនេះកើតឡើង អ្នកដែលបានឃើញ គេសរសើរដល់ពួកសាវក និងអ្នកដែលជឿព្រះយេស៊ូ ហើយពួកគេក៏ជឿព្រះជាម្ចាស់ និងទទួលបានការសង្គ្រោះ។

នេះគឺជាទិដ្ឋភាពរបស់ក្រុមជំនុំដំបូង

**សកម្មភាពទី១** សូមគិតពីមេរៀនដែលបានរៀននៅថ្ងៃនេះ។ ផាត់ពណ៌រូបភាពព្រះវិហារខាងក្រោម រួចកាត់ធ្វើជាព្រះវិហារ។

**សម្ភារៈ៖ កន្ត្រៃ កាវ ខ្មៅដៃពណ៌**




រូបភាពរួចរាល់



**សកម្មភាពទី២** សូមគិតពីមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(កិច្ចការ២:៤)

អ្នកទាំងនោះបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ